
ឫក្ខបក្ខុមហ៉ាតក

# ចូឡបទុមជាតក

*យុនសោភ័ណភក្តី* **អ៊ិម - អន** *ប្រែនិងរៀបរៀង*

*ធម្មតាមនុស្សទាំងអស់ក្នុងលោកនេះ រមែងមានការប្រាស្រ័យទាក់ទងរកគ្នាដោយសេចក្តីសង្គ្រោះទៅវិញទៅមក ដូចយ៉ាងមាតាបិតា និងបុត្តធីតា គ្រូបាអាចារ្យ និងសិស្សានុសិស្ស ស្វាមី និងភរិយាជាដើម។ អ្នកដែលបានធ្វើសេចក្តីសង្គ្រោះគេមុនដំបូងឈ្មោះថាបុព្វការី អ្នកដែលបានទទួលសេចក្តីសង្គ្រោះអំពីសម្នាក់បុព្វការីបុគ្គលនោះ ហើយសម្តែងសេចក្តីតបគុណវិញ ឈ្មោះថាកតញ្ញូកតវេទី, បុគ្គលទាំងពីរពួកនេះ បើបានប្រព្រឹត្តស្មោះត្រង់នឹងគ្នាទៅវិញទៅមក រមែងបានសេចក្តីសុខ-ចម្រើន ក្នុងលោកនេះ និងលោកខាងមុខ ឯបុគ្គលទីពីរដែលហៅថាកតញ្ញូកតវេទីនោះ ឃើញថាកម្រមានណាស់ក្នុងលោកនេះ សម្បូណ៌តែខាងបុគ្គល ដែលរមិលគុណ ឬបំភ្លេចគុណគេចោលដែលហៅថាអកតញ្ញូ។ តាមច្បាប់និយមទុកមកថាៈ អ្នកដែលលុបគុណ រមិលគុណ វេរឃ្លើសគុណគេ នឹងទៅជាមនុស្សអាក្រក់បំផុតក្នុងបណ្តាមនុស្សទាំងអស់ ហើយនឹងត្រូវទទួលរងទុក្ខទោសភ័យអន្តរាយដោយអនេកប្បការ ក្នុងឥធលោក និងបរលោកជាប្រាកដ។ សូមស្រង់យកចូឡបទុមជាតកមកប្រតិស្ឋទុកក្នុងទីនេះ ដើម្បីឲ្យឃើញជាព័ស្តុតាងហើយគ្រាន់ជាគ្រឿងប្រដាប់សតិបញ្ញានៃអស់លោកដូចសេចក្តីតទៅនេះ ៖*

*អតីតេ ពារាណសីរញ្ញោ សត្ត បុត្តា អហេសុំ។*

*តេសំ សព្វជេដ្ឋកោ បទុមោ នាម កុមារោ ពោធិសត្តោ។*

*បពិត្រអើយ ក្នុងកាលដ៏ខ្ពង់ខ្ពស់កំបាំងស្ងាត់កន្លង រំលងយូរណាស់ទៅហើយ ព្វដ៏កាលនោះ ព្រះចៅក្រុងពារាណសី មានព្រះរាជបុត្រ៧អង្គ។ បណ្តាព្រះរាជឱរសទាំង៧អង្គនោះ បទុមរាជកុមារពោធិសត្វជាបងច្បងលើរាជកុមារ*

ទាំងអស់។ កាលនោះព្រះចៅក្រុងពារាណសីជាព្រះវររាជបិតា ទ្រង់ព្រះចិន្តាថាៈ ព្រះរាជកុមារទាំងនេះតទៅមុខជានឹងនាំគ្នាសម្លាប់អញ ហើយដណ្ដើមយករាជសម្បត្តិតែសព្វៗខ្លួនពុំខានឡើយ, លុះទ្រង់ព្រះចិន្តាឈ្វេងយល់ដូច្នេះហើយ ក៏កើតសេចក្ដីរង្កៀសសង្ស័យចំពោះព្រះរាជបុត្រាទាំងនោះ ទើបមានព្រះបន្ទូលថាៈ ហៃបុត្រស្ងួនសំឡាញ់មាសឪពុកទាំងឡាយអើយ! បាកុំនៅក្នុងទីនេះឡើយ ចូរបានាំគ្នាចេញទៅនៅក្នុងទីដទៃសិនទៅ ទម្រាំតែដល់គ្រាដែលអំណឹះឥតអំពីបិតាទៅ សឹមបានាំគ្នាទទួលយករាជសម្បត្តិជាខាងក្រោយចុះ។ ឯព្រះរាជកុមារទាំងនោះ ព្រមទាំងភរិយារបស់ខ្លួន ក៏នាំគ្នាថ្វាយបង្គំលាព្រះវរមាតា បិតាហើយចេញទៅអំពីនគរ លុះដើរៗទៅបានទៅដល់ផ្លូវដាច់ស្រយាលក៏ដាច់បាយដាច់ទឹកនៅក្នុងកណ្ដាលអធ្វា រកស្បៀងអាហារបរិភោគពុំបាន ក៏បបួលគ្នាកាប់សម្លាប់ភរិយានៃព្រះរាជកុមារពៅជាមុន ចែកសាច់ជា៧ចំណែកហើយបរិភោគសាច់ដែលជាចំណែករបស់ខ្លួនតែរៀងៗខ្លួន។

នឹងថ្លែងឯព្រះបរមពោធិសត្វអគ្គមហាបុរសរ័ត្ន ព្រះអង្គត្រូវបានពីរចំណែក គឺព្រះអង្គ១ចំណែក ភរិយារបស់ព្រះអង្គ១ចំណែក។ គឺបណ្ដាចំណែកពីរដែលខ្លួន និងប្រពន្ធបានមកនោះព្រះអង្គបានតម្កល់ទុក១ ចំណែកៗ រៀងរាល់ថ្ងៃមិនបរិភោគឡើយ បរិភោគតែ១ ចំណែកជាមួយនឹងភរិយា។ ឯកុមារទាំងនោះក៏សម្លាប់ស្ត្រីទាំង៦នាក់ ក្នុង១ថ្ងៃមួយៗ យកសាច់មកចែកគ្នាបរិភោគតាមន័យនេះរៀងរាល់ថ្ងៃ រហូតមកដល់ថ្ងៃជាគម្រប់៦។ ចំណែកព្រះបរមពោធិសត្វអគ្គមហាបុរសរ័ត្នហេតុតែព្រះអង្គមានប្រាជ្ញាឈ្លាសវៃ បានរំលែកទុកចំណែកដែលត្រូវបានខ្លួនមួយចំណែកៗ តែរាល់ៗថ្ងៃ ទើបដល់មកថ្ងៃទី៧ ដែលត្រូវវេនសម្លាប់ភរិយារបស់ខ្លួននោះព្រះអង្គនៅសល់ចំណែកទាំង៦ ដែលបានរំលែក

លាក់ទុកពីថ្ងៃមុនៗមក។ ព្រះអង្គក៏បានចំណែកទាំង៦ ដល់ព្រះរាជកុមារទាំងឡាយ ដែលមានប្រាថ្នាដើម្បីនឹងសម្លាប់ភរិយារបស់ព្រះអង្គ ហើយទ្រង់ពោលថាៈ ម្នាលអ្នកទាំងឡាយ ក្នុងថ្ងៃនេះ អ្នកទាំងឡាយ ចូរបរិភោគចំណែកទាំងនេះសិនចុះ ចាំដល់ថ្ងៃស្អែកសឹមយើងនឹងគិតលៃលកតទៅទៀត។ លុះដល់វេលារាត្រី កាលព្រះរាជកុមារទាំងអស់កំពុងដេកលក់ស៊ប់ ព្រះអង្គក៏នាំភរិយារបស់ព្រះអង្គរត់គេចទៅអំពីទីនោះ។ លុះដើរឆ្ងាយបន្តិចទៅភរិយាអស់កម្លាំងមិនអាចដើរទៅទៀតបាន ទើបព្រះអង្គក៏លើកភរិយាបញ្ជិះលើស្មាហើយខំប្រឹងដើរទៅ, កាលព្រះអាទិត្យរះឡើងពេញពន្លឺ ក៏បានឆ្លងផ្លូវឆ្ងាយដាច់ស្រយាលនោះផុត។ ឯភរិយាបាននិយាយថាៈ បពិត្រអ្នកជាស្វាមី ខ្ញុំស្រេកទឹកខ្លាំងណាស់។ ព្រះបរមពោធិសត្វ កាលណាបើរកទឹកពុំបានឲ្យភរិយាផឹក ក៏អារជង្គង់ខ្លួនដោយព្រះខាន់ដ៏មុត យកឈាមឲ្យភរិយាផឹក។ ជនទាំងពីរនាក់ស្វាមីភរិយានោះ ដើរជាលំដាប់ទៅបានដល់មហាគង្គា១ ក៏ធ្វើបណ្ណសាលា១ នៅក្បែរទន្លេគង្គានោះ ហើយក៏នាំគ្នានៅក្នុងទីនោះទៅ។ កាលនោះមានពួកមនុស្សជាច្រើន ចាប់បានចោរម្នាក់ដែលមានទោសកំហុសចំពោះព្រះរាជាហើយនាំយកទៅកាត់ ដៃ ជើង ត្រចៀក និងច្រមុះឲ្យកំបុតអស់ ហើយដាក់នៅក្នុងពោងពាយបណ្តែតចោលទៅក្នុងទន្លេគង្គានោះទៅ។ ឯបុរសកំបុតក៏ស្រែកថ្ងូរដោយសម្រែកដ៏ខ្លាំង ហើយអណ្តែតទៅដល់ទីនោះ។ ព្រះបរមពោធិសត្វបានឮសំឡេងនោះហើយក៏ទៅស្រង់លើកបុរសកំបុតនោះ ដោយសេចក្តីករុណាអាណិតអាសូរនាំយកទៅកាន់បណ្ណសាលា បានធ្វើវណប្បតិកម្ម គឺកិរិយាបិទរុំដំបៅដោយកិច្ចទាំងឡាយមានលាង និងលាបរុំ ដោយសំពត់ជាដើម។ ឯភរិយាព្រះបរមពោធិសត្វមហាបុរសរ័ត្ន ខ្ពើមរអើមបុរសកំបុតនោះពន់ពេក ចេះតែខាកស្តោះៗ រាល់ៗថ្ងៃ។ កាលនោះព្រះ

បរមពោធិសត្វ តែងទុកបុរសកំបុតនោះឲ្យនៅក្នុងអាស្រមជាមួយនឹងភរិយា ហើយទ្រង់ចេញទៅស្វែងរកផលាផលដោយព្រះអង្គឯង នាំយកមកចិញ្ចឹមរក្សា ទ្រង់ថែរក្សាបុរសកំបុតរៀងរាល់ថ្ងៃ ទាល់តែបានសះជារបួសនោះដោយស្រួល បួល។ ឯនាងជាស្រីអប្រិយមានចិត្តគំនិតអាក្រក់ ក្បត់ចិត្តស្វាមីកាលបានឱកាស ស្វាត់ហើយ ក៏លបលួចចងចិត្តប្រតិព័ទ្ធនឹងអាកំបុតឥតមានចិត្តកោតក្រែងដល់ ស្វាមីបន្តិចបន្តួចឡើយ ហើយក៏បានប្រព្រឹត្តមិច្ឆាចារជាមួយនឹងអាកំបុតនោះ ទៅ, មិនតែប៉ុណ្ណោះសោត គិតរកកលឧបាយនឹងសម្លាប់ព្រះពោធិសត្វជាស្វាមី របស់ខ្លួនចោល ហើយក៏ធ្វើជាក្លែងនិយាយថាៈ បពិត្រអ្នកស្វាមី កាលដែលខ្ញុំជិះ លើស្មាអ្នកចេញផុតអំពីផ្លូវឆ្ងាយដាច់ស្រយាលនោះមក បានឃើញភ្នំ១ធំ ហើយខ្ញុំក៏បានតាំងសច្ចាប្រណិធានបួងសួងបន់ស្រន់ថាៈ បពិត្រលោកទេវតា រក្សាភ្នំជាម្ចាស់ខ្ញុំអើយ! បើសិនណាជាខ្ញុំព្រមទាំងស្វាមីរបស់ខ្ញុំជាបុគ្គលឥតមាន ជម្ងឺតម្កាត់អ្វី ហើយបានរស់រួចជីវិតកាលណា ខ្ញុំនឹងត្រឡប់មកធ្វើពលិកម្មបូជា ដល់លោកក្នុងកាលនោះពុំខាន, ឥឡូវនេះដល់ពេលដែលខ្ញុំនឹងត្រូវធ្វើពលិកម្ម បូជាដល់ទេវតានោះ។ នាងថាតែប៉ុណ្ណោះហើយ ក៏នាំព្រះពោធិសត្វទៅឯភ្នំនោះ លុះដល់ហើយទើបនិយាយនឹងព្រះពោធិសត្វជាស្វាមីថាៈ បពិត្រអ្នកជាស្វាមី, ខ្លួនអ្នកជាទេវតាដ៏ឧត្តមបំផុត ខ្ញុំនឹងដើរប្រទក្សិណអ្នក៣ជុំ ហើយថ្វាយបង្គំអ្នក ជាមុនសិន រួចហើយសឹមធ្វើពលិកម្មបូជាដល់ទេវតាក្នុងកាលជាខាងក្រោយ។ ស្រីអប្រិយពោលពាក្យយ៉ាងនេះហើយ ក៏ឲ្យព្រះពោធិសត្វឈរបែរមុខឈម ទៅរកជ្រោះភ្នំ ហើយធ្វើអាការហាក់ដូចជាស្រីមានប្រាថ្នា ដើម្បីថ្វាយបង្គំបូជា ដោយផ្កាភ្ញីទាំងឡាយ ឈរនៅពីខាងក្រោយខ្នងហើយច្រានព្រះពោធិសត្វ ទម្លាក់ទៅក្នុងជ្រោះភ្នំនោះទៅ។ រួចហើយក៏ម្នីម្នាត្រឡប់វិលទៅកាន់សម្នាក់បុរស

កំបុតនោះវិញដោយប្រញាប់ប្រញាល់។ ឯព្រះពោធិសត្វមហាបុរសរ័ត្ន កាលដែលធ្លាក់ចុះទៅក្នុងជ្រោះនោះ ហេតុតែបុណ្យសម្ភារព្រះបារមីដែលព្រះអង្គបានកសាងទុកមកពីបុព្វជាតិ ក៏ធ្លាក់ទៅទើរលើគុម្ពឈើស៊ិមទ្រុម១ លើចុងឧទុម្ពរ (ដើមល្វា)១ដើម ដែលជាឈើឥតបន្លាតែទ្រង់មិនអាចដើរចុះទៅក្នុងទីដទៃបានឡើយ ក៏បេះផ្លែឧទុម្ពរអង្គុយបរិភោគ្គានៅលើប្រគាបមែកឈើនោះឯង។ ជួនជាពេលនោះ មានស្តេចទន្សោង១ មានសរីរាវយវៈដ៏ធំ ជាសត្វធ្លាប់ឡើងអំពីជើងភ្នំទៅរកស៊ីផ្លែល្វានោះ។ សត្វទន្សោងនោះ កាលឡើងមកស៊ីផ្លែឈើនោះស្រាប់តែក្រឡេកមើលទៅឃើញព្រះបរមពោធិសត្វ ក៏មានសេចក្តីវិស្សាសៈស្និទ្ធស្នាលនឹងព្រះអង្គ ទើបសួររកហេតុដែលព្រះពោធិសត្វមកក្នុងទីនោះ, កាលបានស្តាប់ដឹងនូវសេចក្តីនោះសព្វគ្រប់ហើយ ក៏ឲ្យព្រះបរមពោធិសត្វអគ្គមហាបុរសរ័ត្នអង្គុយនៅលើខ្នងរបស់ខ្លួន ហើយវារឡើងអំពីជ្រោះភ្នំនាំចេញទៅដាក់នៅនាមហាមាគ៌ា ហើយក៏ត្រឡប់វិលចូលទៅកាន់ព្រៃបាត់ទៅវិញ។ ឯព្រះបរមពោធិសត្វទ្រង់ទៅកាន់បច្ចន្តគ្រាមហើយនៅក្នុងស្រុកនោះ, លុះអំណើះឥតអំពីព្រះវររាជបិតាទៅក៏បានទទួលសោយរាជ្យជាស្តេច ទ្រង់ព្រះនាមថា ព្រះបាទបទុមរាជ គ្រប់គ្រងរាជសម្បត្តិជាតំណាតវង្សមក ព្រះអង្គបានសាងសាលាសម្រាប់ឲ្យទាន៦ខ្នង ហើយចំណាយទ្រព្យក្នុង១ថ្ងៃ៦សែនកហានណៈឲ្យទានតែរាល់ៗថ្ងៃឥតមានលោះថ្ងៃណាមួយឡើយ។

កាលនោះស្រីបាបអប្រិយកាឡកណ្ណីជួជាតិឥតលក្ខណ៍នោះ បានបញ្ចិះអាកំបុតលើស្មាដើរចេញមកអំពីព្រៃ ត្រាច់ដើរទៅស្វែងរកសូមទានបាយចំណីគេសព្វច្រកល្ហកឥតមានសោះចន្លោះ ក្នុងផ្លូវជាលំនៅនៃមនុស្សម្នាមហាជនផងយកមកចិញ្ចឹមរក្សាបុរសពិការនោះជាធម្មតា កាលបើមានគេសួរថាៈ បុរសនេះ

ត្រូវជាអ្វីនឹងនាង វាក៏តាំងពោលថ្លែងរៀបរាប់ប្រាប់ថា យើងទាំងពីរនាក់ជាបងប្អូនជីដូនមួយនឹងគ្នា គឺខ្លួនខ្ញុំជាជីតាខាងឪពុកខាងឪពុកធំខាងម្ដាយនៃបុរសនេះ, ឯបុរសនេះ ជាកូនរបស់ម្ដាយមីងខ្ញុំ ពួកចាស់ទុំបានផ្សំផ្គុំខ្ញុំឲ្យជាភរិយានៃបុរសពិការនេះ។ ខ្លួនខ្ញុំក៏ស៊ូតែខំប្រឹងថែរក្សាស្វាមីរបស់ខ្លួន សូម្បីមានទោសធ្ងន់ដល់ថ្នាក់ដែលគេត្រូវសម្លាប់ចោលយ៉ាងនេះក៏ដោយ ចេះតែខំត្រាច់ស្វះស្វែងរកសូមទានបាយចំណីគេយកមកចិញ្ចឹមរក្សាគ្នាទៅ។ ពួកមនុស្សបានឮសម្ដីសាសំឮរៀបរាប់កុហកប្រាប់ដូច្នេះហើយក៏គិតថាៈ នាងនេះជាអ្នកមានសេចក្ដីគោរពប្រតិបត្តិប្ដីណាស់តើ ក៏នាំគ្នាឲ្យបាយបបរជាច្រើន បានឲ្យទាំងកញ្ច្រែងផ្ដៅ១យ៉ាងជាប់មាំ ហើយប្រាប់ថាៈ នាងឯងចូរដាក់ប្ដីរបស់នាងឲ្យអង្គុយនៅក្នុងកញ្ច្រែងនេះ ហើយទូលដើរទៅចុះ ដើម្បីកុំឲ្យលំបាកនឹងបញ្ជិះលើស្មាពេក។ នាងនោះក៏ធ្វើតាមបង្គាប់ដែលគេប្រាប់ ដូច្នោះហើយទូលដើររៀងៗ ទៅដល់ក្រុងពារាណសី ក៏ដាក់អាកំបុតចុះអំពីក្បាលឈប់សម្រាកបរិភោគអាហារចំណី ក្នុងសាលាសម្រាប់ឲ្យទាននោះ រួចហើយនឹងត្រាច់រង្គាត់ដើរទៅមុខទៀត។ គាប់ជួនជាពេលនោះព្រះបរមពោធិសត្វ ព្រះអង្គចេញទៅកាន់រោងទាន ដើម្បីព្រះរាជទានម្ហូបចំណីដល់ពួកមនុស្សម្នាមហាជនជងទាំងឡាយ ដោយផ្ទាល់ព្រះហស្តព្រះអង្គឯង រួចហើយត្រឡប់ចូលទៅកាន់ព្រះរាជនិវេសន៍វិញ។ ស្រាប់តែឃើញស្ត្រីនោះត្រង់ផ្លូវដែលទ្រង់យាងចូលទៅ ហើយក៏ត្រាស់សួរអស់មនុស្សម្នាមហាជនទាំងឡាយថាៈ អ្វីនេះហ្នឹង! អស់ពួកមនុស្សទាំងនោះក៏ក្រាបបង្គំទូលថាៈ បពិត្រព្រះសម្មតិទេព នាងនេះជាស្ត្រីមានសេចក្ដីគោរពកោតក្រែងដល់ប្ដីរបស់ខ្លួន។ ព្រះបរមពោធិសត្វ ព្រះអង្គក៏ទ្រង់ប្រើរាជបម្រើឲ្យទៅហៅនាងនោះមក ហើយទ្រង់ជ្រាបច្បាស់ថាជាភរិយារបស់ព្រះអង្គពីដើម ទើបទ្រង់ឲ្យគេលើក

បុរសពិកលពិការនោះចេញមកអំពីខាងក្នុងកញ្ច្រែង ហើយត្រាស់សួរសព្វគ្រប់អន្លើ។ នាងនោះក៏បានថ្លែងសារស័ព្ទសេចក្ដីក្រាបទូលសព្វគ្រប់តាមន័យដែលបានថ្លែងរួចមកហើយក្នុងខាងដើម។ ព្រះរាជទ្រង់ត្រាស់សួរបញ្ជាក់ថាៈ នាងឯងក្រែងជាភរិយារបស់បទុមកុមារជាធីតារបស់ស្ដេចឯណោះមែនឬ? ហើយជាស្រីមានឈ្មោះយ៉ាងនេះបានដឹកឈាមក្នុងជង្គង់របស់អញ ហើយនាងឯងជិតក្បត់ចិត្តអញទៅលបលួចចងចិត្តប្រតិព័ន្ធ ស្រឡាញ់អាកំបុតនេះបានច្រានអញទម្លាក់ទៅក្នុងជ្រោះភ្នំមែនឬ? ឥឡូវនេះ នាងឯងងើលពកថាសមកក្នុងទីនេះដោយស្មានថាអញស្លាប់បាត់ក្នុងជ្រោះភ្នំនោះទៅហើយ។ រួចហើយទ្រង់ត្រាស់បង្គាប់ទៅពួករាជអាមាត្យថាៈ នៃអ្នកទាំងឡាយរាល់គ្នា ចូរអ្នកទាំងឡាយយកអង្រែមកសំពងសម្លាប់អាកំបុតចង្រៃអប្រិយនេះឲ្យធាប់ៗទៅ ហើយចូរនាំគ្នាកាត់ត្រចៀកច្រមុះនៃស្ត្រីបាបអប្រិបកាឡណ្ណីអបលក្ខណ៍នេះឲ្យធាប់កុំទុកវាឡើយ។ ព្រះពោធិសត្វដែលទ្រង់ធ្វើអាការៈគំរាមកំហែងយ៉ាងនេះ ដើម្បីបង្អន់សេចក្ដីក្រោធប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គមិនបានឲ្យគេធ្វើដូច្នោះឡើយ។ រួចហើយព្រះអង្គទ្រង់ប្រើរាជអាមាត្យឲ្យចងកញ្ច្រែងលើក្បាលនាងនោះដូចដើមវិញ ហើយឲ្យដាក់អាកំបុតទៅក្នុងកញ្ច្រែងនោះ ហើយទ្រង់ត្រាស់ឲ្យអាមាត្យនាំចេញទៅចោលឲ្យផុតអំពីព្រំប្រទល់ដែនរបស់ព្រះអង្គ។